**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*****

# កិច្ចព្រមព្រៀង
## ស្តីពី
## នីតិវិធីទូទាត់ជាមួយកម្មករនិយោជិត

នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២១ សមាគមសម្ព័ន្ធភាពបារាំងខេត្តសៀមរាប ដែលមានអាសយដ្ឋាននៅអាគារលេខ ០៩និង១០ ផ្លូវអាចារ្យស្វា នៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប បានធ្វើសំណើសុំព្យួរ កិច្ចសន្យាការងារកម្មករនិយោជិត ដែលមានចំនួនសរុប ១៨នាក់ ក្នុងនោះមាន ស្រី ១៤នាក់ បុគ្គលិកដែលនឹងត្រូវព្យួរកិច្ចសន្យាការងារមានចំនួន ១២នាក់ ក្នុងនោះមាន ប្រុស ០៣នាក់ និងស្រី ០៩នាក់ រយៈពេល ៦១ ថ្ងៃ ដែលគិតចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ដោយសារតែ សមាគមបានផ្អាក សកម្មភាពអប់រំ យោងតាមសេចក្តីជូនដំណឹង របស់ក្រសួងអប់រំ យុវជន និងកីឡាលេខ ២៩អយក.សជណចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១ ស្តីពីការផ្អាកដំណើរការគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនគ្រប់កម្រិតជាបណ្តោះអាសន្ន នៅទូទាំងប្រទេស ដែលជាហេតុធ្វើឲ្យសមាគមសម្ព័ន្ធភាពបារាំងខេត្តសៀមរាប មិនអាចបើកដំណើរការបានទាំងស្រុង និងបាត់បង់ចំណូលសំរាប់ផ្គត់ផ្គង់ចំណាយផ្សេងៗរួមទាំងបើកប្រាក់បៀវត្សជូនបុគ្គលិក។

ក្នុងរយៈពេល នៃការព្យួរកិច្ចសន្យាការងារនេះ សមាគមសម្ព័ន្ធភាពបារាំងខេត្តសៀមរាបមិនបានផ្តល់ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភជូនបុគ្គលិកទេ។

ថ្ងៃព្រហស្បតិ៍ ០៥រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
សៀមរាប ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១
ហត្ថលេខា

Alliance Française
Alliance Française de Siem Reap

តំណាងសមាគមសម្ព័ន្ធភាពបារាំងខេត្តសៀមរាប

តំណាងកម្មករនិយោជិត
ស្នាមមេដៃស្តាំ

១) ........................ ង៉ាវ និមល

២) ........................ ឃឹម ឌាវ៉